LONG BEACH Utilities
Water · Gas · Sewer

# កិច្ចសន្យារបស់អតិថិជន សម្រាប់កម្មវិធីធ្វើសួន

ដោយបានពិចារណាល្អិតល្អន់ និងត្រឹមត្រូវ និងដោយរួមទាំងការអនុញ្ញាតក្នុងការចូលរួមក្នុងកម្មវិធីសាកល្បងធ្វើសួនរបស់នាយកដ្ឋានទឹកភ្លើងក្រុងឡុងប៊ិច ហៅកាត់ថា LBUD នេះ ខ្ញុំក្នុងនាមខ្លួនឯងផង និងក្នុងនាមជាទាយាទ អ្នកស្នងមរតក អ្នកតំណាង អ្នកប្រតិបត្តិ អ្នករដ្ឋបាល និងប្តី/ប្រពន្ធរបស់ខ្ញុំផង៖

- យល់ព្រមថា ខ្ញុំគឺជាម្ចាស់អចលនទ្រព្យ។
- យល់ព្រមថា ខ្ញុំត្រូវចូលរួមក្នុងកម្មវិធីធ្វើសួននេះ ដែលរួមមានការរចនា ការគាស់ស្មៅចេញពីតំបន់គម្រោងធ្វើសួន នៅខាងមុខ និងនៅលើដីជាប់គែមផ្លូវ នៅទីតាំងអចលនទ្រព្យរបស់ខ្ញុំ និងការសង់សួនលម្អថ្មីដែលធន់នឹងអាកាសធាតុរាំងស្ងួត និងរុក្ខជាតិ និងប្រព័ន្ធស្រោចស្រព (តំបន់នៃកម្មវិធីរៀបចំសួនឡើងវិញ)។
- ព្រមព្រៀងតាមលក្ខខណ្ឌចូលរួមកម្មវិធីសម្រាប់អតិថិជន។
- យល់ព្រមដាក់ឯកសារបញ្ជាក់អំពីការបំពេញគ្រប់លក្ខខណ្ឌនៃប្រាក់ចំណូល ដើម្បីយកមកពិចារណាសម្រាប់កម្មវិធីនេះ។
- យល់ព្រមថា ខ្ញុំត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះការរក្សាគុណភាព សោភ័ណភាព និងការថែទាំតំបន់រៀបចំសួនឡើងវិញនោះ។ ការទទួលខុសត្រូវនេះ រួមមាន ប៉ុន្តែមិនកំណត់ត្រឹម សុខភាពរុក្ខជាតិ ថែទាំប្រព័ន្ធស្រោចស្រព ដកស្មៅចង្រៃ និងអនុវត្តតាម Section 14.28.110 នៃក្រុមសាលាក្រុងឡុងប៊ិច ពាក់ព័ន្ធនឹងជំនួយសម្រាប់សត្វល្អិត។
- យល់ព្រមថា ខ្ញុំត្រូវដាក់ឲ្យ LBUD និង/ឬភ្នាក់ងាររបស់ខ្លួន ប្រើប្រាស់តំបន់ដែលត្រូវរៀបចំធ្វើសួនថ្មី និងអចលនទ្រព្យនោះ បានទៅតាមសេចក្តីត្រូវការ ដើម្បីឲ្យភាគីទាំងពីរអាចប្រើប្រាស់វាទាំងក្នុងអំឡុងពេលថតរូប និងក្រោយពេលថតរូប និងវីដេអូនៃតំបន់ដែលត្រូវធ្វើសួនឡើងវិញ សម្រាប់គោលបំណងនៃការផ្សព្វផ្សាយ ដែលការផ្សព្វផ្សាយទាំងនោះអាចមានក្នុងទម្រង់ជាការការបោះពុម្ពផ្សាយ ការផ្សាយតាមអ៊ិនធើណិត ឬមធ្យោបាយផ្សេងទៀត ហើយខ្ញុំព្រមព្រៀងដែរ ថាខ្ញុំមិនត្រូវមានផលប្រយោជន៍កម្មសិទ្ធិណាមួយ នៅក្នុងការរចនានៃតំបន់ដែលត្រូវរៀបចំធ្វើសួនឡើងវិញនោះ ឬប្លង់ ឬឯកសារដទៃទៀត ដែលបញ្ជាក់អំពីការរចនានេះនោះឡើយ។
- យល់ព្រមថា ខ្ញុំត្រូវផ្តល់ជូនសាលាក្រុង និងនាយកដ្ឋានផ្សេងរបស់ក្រុង (និងលើសពី LBUD) ក្រុមប្រឹក្សាគណៈកម្មការ នាយក មន្ត្រី និយោជិត ភ្នាក់ងារ និងអ្នករចនាប្លង់ (ជារួមគឺ"ក្រុង") នូវការអនុញ្ញាតដែលមិនអាចលុបចោលវិញមួយបាន ដើម្បីថតរូប និងភិនភាគ និង/ឬរូបភាពនៃតំបន់ដែលត្រូវរៀបចំសួនឡើងវិញរបស់ខ្ញុំ និងរូបអចលនទ្រព្យជាក់ស្តែង និងផ្ទាល់ខ្លួនរបស់ខ្ញុំ ដោយមានទាំងរូបវីដេអូ រូបថតមានចលនា ខ្សែអាត់សំឡេង និងរូបភាពផ្សេងទៀត (ហៅជារួមថា "រូបភាព")។ ខ្ញុំទទួលស្គាល់ថា រូបភាពទាំងនោះជារបស់សាលាក្រុងឡុងប៊ិច និងខ្ញុំផ្តល់សិទ្ធិអនុញ្ញាផ្ទេរកម្មសិទ្ធិបញ្ញាដល់សាលាក្រុងក្នុងការដាក់បង្ហាញ ផ្សព្វផ្សាយ ចែកចាយ ប្រើប្រាស់ កែរូប បោះពុម្ព និងបោះពុម្ពឡើវិញ ក្នុងទម្រង់ណាមួយទៅតាមសេចក្តីត្រូវការរបស់សាលាក្រុង រួមទាំងការពុំមានភាពកំហិតក្នុងបោះពុម្ព ការផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណផ្សព្វផ្សាយ រូបភាពសម្រាប់គេហទំព័រ ឬ ការបង្ហាញតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត និងការបញ្ជូនរូបភាពទាំងនេះផង។ ខ្ញុំលះបង់សិទ្ធិរបស់ខ្លួនទាំងអស់ ក្នុងការពិនិត្យ ឬឯកភាពជាមុនលើរូបទាំងនោះ មុនសាលាក្រុងប្រើប្រាស់វា។ ខ្ញុំសូមលះបង់ការទាមទារឲ្យសាលាក្រុងទទួលខុសត្រូវណាមួយ ដែលកើតចេញពីការប្រើប្រាស់រូបភាពទាំងនោះ ទៅក្នុងទម្រង់ណាមួយ ឬតាមប្រព័ន្ធផ្សព្វផ្សាយណាមួយ និងប្រកាសឲ្យសាលាក្រុងរួចពីសំណង និងការប្តឹងផ្តល់ផ្សេងៗ ពាក់ព័ន្ធនឹងការប្រើប្រាស់រូបភាពទាំងនោះ ដោយរួមទាំងការមិនដាក់កំហិត ការប្តឹងទាមទារអំពីការបំពានសិទ្ធិឯកជនភាព ឬសិទ្ធិផ្សព្វផ្សាយជាសាធារណៈ។
- ឲ្យសាលាក្រុងរួចផុតពីការទទួលខុសត្រូវទាំងអស់ ពាក់ព័ន្ធនឹងកម្មវិធីធ្វើសួន តំបន់ដែលត្រូវរៀបចំសួនឡើងវិញ ឬសេវាម៉ៅការ ឬផលិតផលទាំងឡាយ ដែលត្រូវធ្វើជាផ្នែកនៃកម្មវិធីនេះ។ ការទាមទារណាមួយពីខ្ញុំអាចផ្អែកលើការខូចខាត ឬខកខានក្នុងការបំពេញសេវាទៅតាមការសន្យា ឧបករណ៍ ឬសម្ភារៈដែលផ្តល់ជូនដោយកម្មវិធីនេះ ត្រូវដាក់ប្តឹងទៅអ្នកម៉ៅការ ឬរោងចក្រផលិត/អ្នកចែកចាយ។ LBUD មិនតំណាង ឬធានាអ្វីមួយ ពាក់ព័ន្ធទៅនឹងសេវា ឬផលិតផលដែលបានព្រមព្រៀងគ្នា ដែលអាចត្រូវដំឡើងជាផ្នែកមួយនៃកម្មវិធីនេះនោះឡើយ។ តាមរយៈនៃការចូលរួមកម្មវិធីនេះ បងប្អូនបោះបង់សិទ្ធិ និងមិនឲ្យសាលាក្រុង អ្នកម៉ៅការរបស់សាលាក្រុង និងភ្នាក់ងារសាលាក្រុង ជាប់ការទទួលខុសត្រូវអ្វីមួយ ពីរាល់ការទាមទារ និងការប្តឹងផ្តល់ណាមួយ ដែលកើតចេញពីការទិញ ដំឡើង ឬការប្រើប្រាស់របស់របរ និងសម្ភារៈពាក់ព័ន្ធនឹងកម្មវិធីនេះ។
- តាមរយៈនៃការចុះហត្ថលេខាលើឯកសារនេះ ខ្ញុំសូមបញ្ជាក់ថា រាល់ព័ត៌មានដែលផ្តល់ជូនទាំងអស់ គឺពិត និងត្រឹមត្រូវទៅតាមការយល់ដឹងរបស់ខ្ញុំ ហើយខ្ញុំយល់ព្រមអនុវត្តតាមការទទួលខុសត្រូវ និងលក្ខខណ្ឌចូលរួមកម្មវិធីនេះ ព្រមទាំងគោរពតាមក្រមរបស់ជាតិ រដ្ឋ និងមូលដ្ឋាន រួមមានកិច្ចព្រមព្រៀង គោលនយោបាយ លក្ខខណ្ឌ និងការកំហិតផ្សេងដែលនៅជាធរមាន។ ជាងនេះទៅទៀត ខ្ញុំយល់ព្រមលះបង់សិទ្ធិទាមទារការទទួលខុសត្រូវរបស់សាលាក្រុង ប្រធាននាយដ្ឋានក្រុង មន្ត្រីក្រុង និងនិយោជិតក្រុងទាំងអស់ ដោយមិនឲ្យជាប់ការទទួលខុសត្រូវរឿងបាត់បង់ សំណង ការខូតខាត ឬការទទួលខុសត្រូវអ្វីមួយ ដែលកើតចេញពីការធ្វើសួន ឬការប្រើប្រាស់សួននេះ

លើកលែងតែករណីដែលកើតចេញពីការធ្វេសប្រហែសធ្ងន់ធ្ងរ ឬចេតនាប្រព្រឹត្តមិនត្រឹមត្រូវរបស់សាលាក្រុង និង/ឬអ្នកម៉ៅការរបស់ក្រុង។

ឯកសារនេះបញ្ជាក់អំពីការឲ្យសាលាក្រុង និងអ្នកដទៃទៀត រួចពីការទទួលខុសត្រូវចំពោះរបួសស្នាម បំណុល និងការខូតខាតដោយសារការធ្វេសប្រហែស។ ខ្ញុំបានអានឯកសារនេះ បានយល់ថា ខ្ញុំបានលះបង់សិទ្ធិសំខាន់ៗជាច្រើន និងសុខចិត្តប្រឈមនឹងហានិភ័យទាំងអស់ពីការចុះហត្ថលេខានេះ និងព្រមចុះហត្ថលេខាដោយស្ម័គ្រចិត្ត។

ឈ្មោះ ____________________ ហត្ថលេខា ____________________ កាលបរិច្ឆេទ ____________________